


# សេវាកម្មសវនកម្ម និងការធានា

គុណភាព គឺជាបណ្តូលបេះដូងរបស់ក្រុមហ៊ុន អេចអិលប៊ី អឌីត & ផាតនើរ វាត្រូវបានបង្កប់នៅក្នុងអ្វីគ្រប់យ៉ាងដែលយើងធ្វើ។ ដូច្នេះ នៅពេលនិយាយអំពីការជ្រើសរើសអ្នកជំនាញសម្រាប់ការងារសវនកម្មរបស់អ្នក អ្នកអាចមានទំនុកចិត្តលើក្រុមអ្នកសវនករ អេចអិលប៊ី HLB របស់យើង ។ ដោយសារគុណភាពសវនកម្មមានសារៈសំខាន់ជាមូលដ្ឋានក្នុងការរក្សាការជឿទុកចិត្តលើដំណើរការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុ ក្រុមអ្នកជំនាញសវនកម្ម និងការធានា ទាំងក្នុងស្រុក និងអន្តរជាតិ របស់ HLB ធានាថា ការធ្វើសវនកម្មរបស់អ្នក ត្រូវបានអនុវត្តស្របតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្ម (ISA) និងអនុលោមតាមស្តង់ដារអន្តរជាតិស្តីពីការត្រួតពិនិត្យគុណភាព (ISQC 1)។

មធ្យោបាយមួយដែលយើងបង្ហាញពីការប្តេជ្ញាចិត្តរបស់យើង នោះមិនត្រឹមតែរក្សាគុណភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកែលម្អគុណភាពឱ្យប្រសើរឡើង គឺតាមរយៈសមាជិកភាពរបស់យើងនៃវេទិកាជួបជុំសមាជិកក្រុមហ៊ុនទាំងអស់ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធ។ ក្នុងនាមជាបណ្តាញមួយ យើងយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះសមាជិកភាពរបស់យើងនៃវេទិកាក្រុមហ៊ុន Forum of Firms ហើយមានមោទនភាពក្នុងការតំណាង និងផ្តល់សំឡេងដល់ទីផ្សារកម្រិតមធ្យមនៅលើឆាកអន្តរជាតិ។

ក្រុមការងាររបស់យើង បានសហការជាមួយអ្នកជំនាញសវនកម្ម និងការធានា ទាំងក្នុងស្រុក និងអន្តរជាតិ ផ្តល់សេវាកម្មដល់អតិថិជនជាច្រើនប្រភេទ នៅគ្រប់ឧស្សាហកម្ម និងវិស័យផ្សេងៗទៀត។ ក្រៅពីការផ្តល់សេវាសវនកម្មស្របតាមច្បាប់ ការផ្តោតសំខាន់ៗរបស់យើង រួមមាន៖ សវនកម្មផ្ទៃក្នុង សវនកម្មអនុលោមតាមបទប្បញ្ញត្តិនិងច្បាប់ សវនកម្មក្នុងគោលបំណងពិសេសនិងការពិនិត្យឡើងវិញ ព្រមទាំងសេវាកម្មធានានិងប្រឹក្សាផ្នែកហានិភ័យ។

# គណៈកម្មការត្រួតពិនិត្យធានាគុណភាព

ដោយការធានាគុណភាព គឺជាគន្លងស្នូលនៃយុទ្ធសាស្ត្រ HLB Cambodia ជារឿងធម្មតា ដែលវាកិច្ចការរបស់ គណៈកម្មាការត្រួតពិនិត្យ ធានាគុណភាព (QAIC) ដែរមានសមាជិកមកពីក្រុមអ្នកជំនាញវិជ្ជាជីវៈក្នុងស្រុក និងអន្តរជាតិ មកចូលរួមក្នុងក្រុមរបស់យើង។

ជារៀងរាល់ឆ្នាំ HLB Global រៀបចំសន្និសីទប្រចាំឆ្នាំដើម្បីចែករំលែកព័ត៌មានពីបច្ចេកទេសថ្មីៗ និងការបណ្តុះបណ្តាលសមាជិកក្នុងតំបន់។ ការធានាគុណភាព ដើរតួនាទីយ៉ាងសំខាន់ក្នុងការងារនេះ ដែលសមាជិករបស់ QAIC រួមជាមួយក្រុមគ្រប់គ្រងគម្រោង និងក្រុមអ្នកត្រួតពិនិត្យផ្ទៃក្នុងបានទទួលការបណ្តុះបណ្តាលខ្ពស់ដើម្បីធានាថា គុណភាពសវនកម្ម របស់ក្រុមហ៊ុន HLB Cambodia ត្រូវបានត្រួតពិនិត្យជាប្រចាំ។

សមាជិកគណៈកម្មការដែលមានបទពិសោធន៍របស់យើង បានបង្កើតកម្មវិធីពិសេសមួយ ដែលភ្ជាប់ការវាយតម្លៃគ្រប់គ្រងគុណភាព ជាមួយនិងការវិភាគមូលហេតុដើមនៃព្រឹត្តិការណ៍ និងការអភិវឌ្ឍចំណេះដឹងបន្ថែម ដើម្បីធានាថា ចំណុចដែលល្អបំផុតត្រូវបានអនុវត្តដោយក្រុមនៃសមាជិកផ្ទៃក្នុងរបស់យើង និងត្រូវបានទទួលស្គាល់ដោយ HLB Global។
ធាតុផ្សំទាំងអស់នេះរួមបញ្ចូលគ្នា ដើម្បីឱ្យអ្នកជំនាញសវនកម្មរបស់យើង អាចនាំមកនូវគុណតម្លៃបន្ថែមដល់ការចូលរួមសវនកម្មនីមួយៗ។

## MEET THE TEAMS



**កែវ វិសា**, *CPA, ACCA*
ដៃគូសវនកម្ម



**លី តេងហួ**, *ACCA*
អ្នកគ្រប់គ្រងជាន់ខ្ពស់សវនកម្ម



**អ៊ូច សុភ័ក្រ្ត**
អ្នកគ្រប់គ្រងសវនកម្ម



**គិត ចាន់ថន**
*DBA, MIPA, AFA, CMA*
នាយកប្រតិបត្តិ



**ប៉ាន់ ចំរើន**
*DBA, MIPA, AFA*
ដៃគូធានាគុណភាព | ប្រឹក្សាយោបល់

# TOGETHER WE MAKE IT HAPPEN

THE GLOBAL ADVISORY AND ACCOUNTING NETWORK

www.hlbauditpartners.com.kh
+855 (0) 77 92 42 80 | +855 (0) 15 222 910
+855 (0) 10 412 316 | +855 (0) 17 573 800
info@hlb-cambodia.com

© 2015 - 2026 HLB Cambodia. All rights reserved.
HLB CAMBODIA members are members of HLB International, the global network of advisory and accounting firms. HLB refers to the HLB International network and/or one or more of its member firms.